# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អគ្គលេខាធិការដ្ឋាន**

## របាយការណ៍ស្តីពីដំណើរការនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### I- សេចក្តីផ្តើម

ពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅក្នុងអាណត្តិទី១ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានផ្តោត ការយកចិត្តទុកដាក់ទៅលើការកែលំអ និងបង្កើតលិខិតបទដ្ឋានទាំងឡាយដែលជាគ្រឹះ នៃការអភិវឌ្ឍន៍ ធានានូវ កម្មសិទ្ធិឯកជន សិទ្ធិសេរីភាពរបស់បុគ្គល យន្តការសំរាប់សេដ្ឋកិច្ចទីផ្សារសេរី។ល។

នៅក្នុងអាណត្តិទី២ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានបង្កើតរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង គឺក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ដែលមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម ឌិត មន្ទី ប្រធានតុលាការកំពូលជា សហប្រធាន។ ចាប់តាំងពីពេលនោះមក កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏កាន់តែមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅបន្ថែមទៀត ហើយនឹងត្រូវបានចាត់ទុកជាកត្តាមួយយ៉ាងសំខាន់សំរាប់ទ្រទ្រង់ដល់ការអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល។

យ៉ាងណាមិញ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ ត្រូវបានចាត់ទុកជាកម្មវិធីមួយក្នុងចំណោម កម្មវិធីទាំងបួនយ៉ាង នៃ “អភិបាលកិច្ចល្អ” ដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា នៃរាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា ហើយនិងរួមចំណែកធ្វើឱ្យរាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលធំៗ រួមមាន ការរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ សង្គម កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងកំរិតពីរខ្ទង់ ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការគ្រប់គ្រងបាន នូវកំរិតអតិផរណា ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ភាពជាដៃគូល្អរវាងរាជរដ្ឋាភិបាលជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការរក្សាបាននូវឋានៈជាសមាជិក ស្មើភាព និងស្មើសិទ្ធិក្នុងអង្គការនានា ក្នុងកំរិតតំបន់ និងពិភពលោក។

ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានផ្អែកទៅតាមខ្លឹមសារ នៃឯកសារសំខាន់ពីរគឺ ៖ ១- ឯកសារស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ឯកសារនេះត្រូវបានរៀបចំឡើង តាមរយៈការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ និងត្រូវបានទទួលការអនុម័ត ឯកភាពពីរាជរដ្ឋាភិបាលក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។ ២-ឯកសារស្តីពីផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលត្រូវបានទទួលការ ឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

គោលដៅរួមដែលបានកំណត់សម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌គឺ “ការបង្កើតវិស័យច្បាប់ និងតុលាការមួយដែលអាចជឿទុកចិត្តបាន និងមានស្ថិរភាពសម្រាប់ទ្រទ្រង់គោលការណ៍សិទ្ធិបុគ្គល ការបែងចែក អំណាចដាច់ពីគ្នា និងនីតិរដ្ឋ នៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីតាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចនាំមុខ ដោយវិស័យឯកជន” ។

គោលដៅនេះបង្កើតបានទិសដៅជាយុទ្ធសាស្ត្រដែលស្របតាមតម្លៃ និងគោលការណ៍នៃរដ្ឋធម្មនុញ្ញ និង គោលដៅជាទូទៅក្នុងការគាំទ្រការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ចំនួន ៧ ដូចខាងក្រោម ៖

ទិសដៅជាយុទ្ធសាស្ត្រទី ១ គឺ ការលើកម្ពស់ការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល

ទិសដៅជាយុទ្ធសាស្ត្រទី ២ គឺ ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់

ទិសដៅជាយុទ្ធសាស្ត្រទី ៣ គឺ ផ្តល់លទ្ធភាពទទួលបានព័ត៌មានអំពីច្បាប់ និងតុលាការ

ទិសដៅជាយុទ្ធសាស្ត្រទី ៤ គឺ ធ្វើឱ្យប្រសើរឡើងនូវគុណភាព នៃដំណើររឿងក្តី និងសេវាកម្មពាក់ព័ន្ធ

ទិសដៅជាយុទ្ធសាស្ត្រទី ៥ គឺ ពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ

ទិសដៅជាយុទ្ធសាស្ត្រទី ៦ គឺ បញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ទិសដៅជាយុទ្ធសាស្ត្រទី៧ គឺ ពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការឱ្យបំពេញអាណត្តិរបស់ខ្លួនបាន សម្រេច

សកម្មភាពចំនួន៩៧ ត្រូវបានដាក់ចេញ ដើម្បីធ្វើឱ្យសម្រេចបាននូវលទ្ធផលរំពឹងទុកនៃទិសដៅ ជាយុទ្ធសាស្ត្រ ទាំង៧ ខាងលើ ។

## II- លទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាព

ការងាររៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ តុលាការត្រូវបានសន្មតថា ចប់សព្វគ្រប់នៅពេលដែលគណៈរដ្ឋមន្ត្រី បានពិនិត្យ និងផ្តល់ការឯកភាពលើឯកសារស្តីពី “កម្មវិធីសកម្មភាព សម្រាប់ការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ” លទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពកំណែ ទម្រង់ច្បាប់ និងតុលាការ មានដូចខាងក្រោម ៖

ក-លទ្ធផលនៃការដោះស្រាយបញ្ហាប្រឈមមុខ

នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ រាជរដ្ឋាភិបាល បានផ្តល់ការ ឯកភាពលើវិធានការមួយចំនួនសម្រាប់ដោះស្រាយបញ្ហាប្រឈមមុខ ២ គឺបញ្ហាទប់ស្កាត់អំពើពុករលួយនៅក្នុង តុលាការ និងបញ្ហាកកស្ទះសំណុំរឿងនៅតុលាការ ។

ការទប់ស្កាត់អំពើពុករលួយនៅតុលាការ

អនុលោមតាមយុទ្ធសាស្ត្រ "កណ្តាប់ដៃដែក" របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានធ្វើការតែងតាំង តម្លើងថ្នាក់ ផ្លាស់ប្តូរចៅក្រម និងព្រះរាជ-អាជ្ញា តាមនីតិវិធីត្រឹមត្រូវ និងបានដាក់វិន័យដល់ចៅក្រម និងព្រះរាជអាជ្ញា ចំនួន ១០៧ នាក់ ក្នុងចំណោម ២៩៧ នាក់

រាជរដ្ឋាភិបាល បានស្នើអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោះស្រាយថវិកាសម្រាប់ ការចុះស៊ើបអង្កេត រឿងក្តី

- បានពង្រឹងការងារអធិការកិច្ចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌
- ការដោះស្រាយបញ្ហាកកស្ទះសំណុំរឿង
- បានដោះស្រាយបន្ទប់សវនាការបន្ថែមជូនតុលាការក្រុងភ្នំពេញ និងដោះស្រាយសាលាជំរះក្តីនៅខេត្តដែល មានការខ្វះខាតតាមលទ្ធផល
- បានពង្រឹងភារកិច្ចរបស់គណៈមេធាវីក្នុងការផ្តល់នូវមេធាវីអោយបានគ្រប់គ្រាន់តាម តម្រូវការរបស់តុលា-ការខេត្ត ក្រុងនានា
- បានដោះស្រាយមធ្យោបាយដឹកជញ្ជូនជនជាប់ចោទ ដែលត្រូវចូលសវនាការនៅតុលាការ
- បានដោះស្រាយបញ្ហាសំណុំរឿងចាស់ៗ ដែលទុកចោលមិនបានចាត់ការ
- បានដោះស្រាយបញ្ហាបញ្ជូន និងបង្វិលដីកាកោះ ។

## ខ-លទ្ធផលសំខាន់ៗតាមទិសដៅជាយុទ្ធសាស្ត្រ

ទិសដៅជាយុទ្ធសាស្ត្រទី ១ ៖

ទិសដៅជាយុទ្ធសាស្ត្រទី ១ ស្តីពីការការពារសិទ្ធិសេរីភាពរបស់បុគ្គល សំដៅធ្វើអោយសិទ្ធិ សេរីភាពបុគ្គល ត្រូវបានជំរុញ និងបង្កលក្ខណៈអោយមានការងាយស្រួលក្នុងការអនុវត្ត ។ សកម្មភាពដែលរៀបចំឡើងសម្រាប់ សម្រេចទិសដៅនេះ រួមមានការលើកកំពស់ការយល់ដឹង អំពីសិទ្ធិមនុស្ស តាមរយៈការបណ្តុះបណ្តាលទាំងនៅកំរិត មូលដ្ឋាន ទាំងនៅសាលារៀន (បឋម មធ្យម និងឧត្តម) និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ការបង្កើតច្បាប់ ពាក់ព័ន្ធផ្សេងៗ មានជាអាទិ៍ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ ច្បាប់អង្គការ មិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីលទ្ធភាពទទួលបានព័ត៌មាន ហើយទីបញ្ចប់គឺការគិតគូរដល់ ការបង្កើតស្ថាប័នសម្រាប់ ការពារសិទ្ធិសេរីភាពនេះទៀត រួមមានស្ថាប័នចុះបញ្ជីកម្មសិទ្ធិ និងស្ថាប័នសម្រាប់ប្តឹងតវ៉ា ។

លទ្ធផលជាក់ស្តែងមាន ៖

- កំពុងរៀបចំអនុវត្តគម្រោងស្តីពីការលើកកំពស់ការយល់ដឹងសិទ្ធិមូលដ្ឋាននៅកំរិតសហគមន៍ និងគ្រឹះស្ថាន សហគ្រាស
- បានអនុវត្តការបញ្ចូលសិទ្ធិមនុស្ស/ពលរដ្ឋវិជ្ជា ក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សា (ថ្នាក់ទី១០-១១ និង ១២) តាមជម្រួមណ្ឌលគរុកោសល្យ គ្រឹះស្ថានជំនាញនៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន (ឆ្នាំទី ១)
- ក្រុមការងារអន្តរក្រសួងកំពុងយកចិត្តទុកដាក់ពិនិត្យឡើងវិញ នូវសេចក្តីព្រាងច្បាប់ស្តីពីអង្គការមិន មែនរដ្ឋាភិបាល
- កំពុងអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន ដែលនៅជាធរមាន
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការការពារជនរងគ្រោះ ត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៥។ ក្រសួងកិច្ចការនារីកំពុងចុះផ្សព្វផ្សាយច្បាប់នេះ ហើយការអនុវត្ត កំពុងដំណើរការហើយ
- បានបង្កើតផ្នែកពិសេស ដើម្បីដោះស្រាយទំនាស់ពាក់ព័ន្ធនឹងស្ត្រី និងកុមារនៅតាមស្នងការនគរបាល
- កំពុងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងអំពីច្បាប់ភូមិបាល និងលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់នេះ
- កំពុងអនុវត្តគម្រោងបង្ការបទល្មើសនៅខេត្តកណ្តាលសម្រាប់ ៤៥ ឃុំ ក្នុងស្រុកចំនួន ១១ និងពង្រីក ទៅខេត្ត ៥ ទៀត គឺ បាត់ដំបង ព្រៃវែង កំពង់ធំ កំពង់ចាម និងបន្ទាយមានជ័យ
- ធ្វើការបណ្តុះបណ្តាលដល់ជនជាតិភាគតិចអំពីសិទ្ធិមនុស្ស និងច្បាប់ជាមូលដ្ឋាននៅខេត្តរតនគីរី និង មណ្ឌលគីរី។

ទិសដៅជាយុទ្ធសាស្រ្តទី ២

ទិសដៅជាយុទ្ធសាស្រ្តទី ២ គឺទំនើបកម្មក្របខ័ណ្ឌច្បាប់ សំដៅធ្វើអោយដំណើរការនៃការធ្វើច្បាប់ និង ក្របខ័ណ្ឌច្បាប់ ត្រូវបានធ្វើទំនើបកម្មក្នុងគោលបំណងអនុវត្តនីតិរដ្ឋផ្អែកលើប្រព័ន្ឋានានុក្រមនៃច្បាប់ និងលិខិត បទដ្ឋាន ។

ការខិតខំប្រឹងប្រែងនៅក្នុងទិសដៅនេះ គឺការរៀបចំនូវក្របខ័ណ្ឌច្បាប់សម្រាប់វិស័យច្បាប់ និងតុលាការ ទាំងមូល រួមទាំងច្បាប់បង្កើតស្ថាប័ន និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ដែលតម្រូវដោយរដ្ឋធម្មនុញ្ញ ។

យើងបាន និងកំពុងអនុវត្តការងារទាំងនោះប្រកបដោយផ្លែផ្កា ទោះបីត្រូវការពេលវេលាច្រើនបន្តិចក៏ ដោយ ប៉ុន្តែច្បាប់ដែលយើងព្រាងបាន ដែលយើងតាក់តែងបាន គឺអនុវត្តទៅតាមនីតិវិធីនៃការចូលរួមបានល្អ មាន លក្ខណៈរឹងមាំយូរអង្វែង និងសំរាប់បំរើតុលាការ នីតិប្រតិបត្តិ ការបោះឆ្នោត អន្តោប្រវេសន៍ សារព័ត៌មាន កិច្ចសន្យា រដ្ឋប្បវេណី ព្រហ្មទណ្ឌ គ្រួសារ ភូមិបាល ជលផល បរិស្ថាន មរតកវប្បធម៌ សុខភាព ឱសថ សេដ្ឋកិច្ច ការងារ សណ្តាប់ធ្នាប់ ពន្ធនាគារ មជ្ឈមណ្ឌលយុវនីតិសម្បទា នគរបាល យោធា អាវុធ ចរាចរផ្លូវគោក និងច្បាប់ពាក់ព័ន្ធ និងសន្ធិសញ្ញាអន្តរជាតិដែលគ្រប់ដណ្តប់លើសិទ្ធិមនុស្ស សិទ្ធិនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច

វប្បធម៌ ស្ត្រីភេទ កុមារ ។ល។ ហើយមានចំនួនទាំងអស់ ១៤០ ហើយដែលបាន ប្រកាសឱ្យប្រើនៅអាណត្តិទី ៣ នៃរដ្ឋសភា (សូមមើលឧបសម្ព័ន្ធ)។

លទ្ធផលជាក់ស្តែងមាន ៖

- បានប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណីកាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ និងចូលជាធរមាន នៅខែកក្កដា ២០០៧
- បានប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណីនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧
- សេចក្តីព្រាងក្រមព្រហ្មទណ្ឌ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩
- ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាមួយក្រសួងយុត្តិធម៌ កំពុងពិនិត្យឡើងវិញសេចក្តី ព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា សេចក្តីព្រាងច្បាប់អង្គការស្តីពីការចាត់តាំង អង្គការតុលាការ និងអយ្យការ សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ក្រសួងយុត្តិធម៌កំពុងរៀបចំសេចក្តីព្រាងលក្ខន្តិកៈក្រឡាបញ្ជី
- សេចក្តីព្រាងច្បាប់ប្រឆាំងនឹងអំពើពុករលួយ ត្រូវបានរៀបចំរួចហើយ តែនៅរង់ចាំការអនុម័តក្រម ព្រហ្មទណ្ឌជាមុនសិន
- សារាចរណែនាំសម្រាប់ការតាក់តែងច្បាប់ ត្រូវបានត្រួតពិនិត្យឡើងវិញរួចហើយ នៅតែដាក់ជូន គណៈរដ្ឋមន្ត្រីអនុម័តតែប៉ុណ្ណោះ
- ក្រសួងទំនាក់ទំនងជាមួយសភា និងអធិការកិច្ច បានព្រាងគោលនយោបាយពាក់ព័ន្ធនឹងលទ្ធភាពទទួល បានព័ត៌មាន ហើយកំពុងតែធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា
- ក្រសួងពាណិជ្ជកម្មកំពុងតាក់តែងសេចក្តីព្រាងច្បាប់បង្កើតតុលាការពាណិជ្ជកម្ម ។

ទិសដៅជាយុទ្ធសាស្ត្រទី ៣ ៖

ទិសដៅជាយុទ្ធសាស្ត្រទី ៣ គឺការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មាន ផ្នែកច្បាប់ និងយុត្តិធម៌ សំដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់ និងយុត្តិធម៌ អោយបានកាន់តែល្អឡើង ។ សកម្មភាពក្នុង ផ្នែកនេះមានជាអាទិ៍ ការបង្កើនការបោះពុម្ពច្បាប់ និងសេចក្តីសម្រេចជាស្ថាពររបស់តុលាការ គឺការរៀបចំធ្វើ យ៉ាងណាអោយព័ត៌មានទាំងនោះបានដល់ដៃរបស់អ្នកត្រូវការ និងមានសម្រាប់អ្នកទាំងនោះ ។

ចំពោះការងារផ្នែករាជកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី បានតម្លើងនាយកដ្ឋានរាជកិច្ច ទៅជាអគ្គនាយកដ្ឋាន រាជកិច្ច និងសេវាកុំព្យូទ័រ ដើម្បីពង្រឹង និងពង្រីកសមត្ថភាពបោះពុម្ពផ្សាយ

របស់ខ្លួន។ ការបោះពុម្ពផ្សាយនូវរាជកិច្ច និងទិន្នន័យព័ត៌មានច្បាប់ កំពុងអនុវត្តទៅដោយទៀងទាត់ ។

លទ្ធផលជាក់ស្តែងមាន ៖

- ការតាក់តែងសទ្ទានុក្រមពាក្យច្បាប់ជាបីភាសា ដោយគណៈកម្មាធិការបណ្ឌិតសភាទទួលបន្ទុកអនុម័ត ពាក្យច្បាប់កំពុងមានដំណើរការទៅមុខ
- ការប្រមូល និងការបោះពុម្ពសេចក្តីសម្រេចរបស់តុលាការកំពូល និងសេចក្តីសម្រេចជាស្ថាពរ របស់ តុលាការខេត្ត ក្រុង កំពុងតែដំណើរការទៅមុខ
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ នៃទីស្តីការគណៈរដ្ឋមន្ត្រី បានធ្វើការបោះពុម្ពផ្សាយរាជកិច្ច ជារៀងរាល់សប្តាហ៍ និងជា CD-Rom មួយត្រីមាសម្តង។

ទិសដៅជាយុទ្ធសាស្ត្រទី ៤ ៖

ទិសដៅជាយុទ្ធសាស្ត្រទី ៤ ទាក់ទងដល់ការធ្វើអោយប្រសើរឡើងនូវគុណភាពនៃដំណើរការរឿងក្តី និង សេវាពាក់ព័ន្ធ សំដៅធ្វើឱ្យដំណើរការត្រឹមត្រូវចំពោះមុខស្ថាប័នរដ្ឋបាល និងតុលាការ និងសិទ្ធិនៃការប្តឹងតវ៉ារបស់ ជនគ្រប់រូបត្រូវបានធានា។ សកម្មភាពដែលត្រូវធ្វើក្នុងផ្នែកនេះ គឺការផ្តល់សេវាជំនួយផ្នែកច្បាប់ឱ្យមានគុណភាព ខ្ពស់ ស្របទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ រួមមានការបង្កើនចំនួនមេធាវី ដែលឆ្លងកាត់ការបណ្តុះ បណ្តាលការអនុវត្តក្រមសីលធម៌មេធាវីអោយបានល្អប្រសើរ ការបង្កើតអោយមានបទបញ្ញត្តិពាក់ព័ន្ធនៅក្នុងក្រមនីតិវិធីនានា ។ល។

កិច្ចការនេះពាក់ព័ន្ធយ៉ាងច្រើនដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែរាជរដ្ឋាភិបាល ក៏មិន ប្រងើយកន្តើយដែរ។ ការស្ទង់មតិមួយត្រូវបានធ្វើរួចហើយ លើជំនួយផ្នែកច្បាប់ ហើយអង្គភាពគ្រប់គ្រង គម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នឹងត្រៀមសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បី អនុវត្តនូវផែនការសកម្មភាពមួយចំនួន ដែលកើតចេញពីអនុសាសន៍នៃការស្ទង់មតិនេះ ។ ការរៀបចំនូវគោល នយោបាយ និងបទបញ្ញត្តិច្បាប់ស្តីពីតំណាងផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់នេះ រួមទាំងការពិនិត្យមើលឡើងវិញ នូវច្បាប់ស្តីពីលក្ខន្តិកៈនៃមេធាវី និងការងារបណ្តុះបណ្តាល ។

លទ្ធផលជាក់ស្តែងមាន ៖

- កំពុងអនុវត្តគម្រោងសម្រាប់ជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រដោយគណៈមេធាវី យោងតាម របាយការណ៍ស្រាវជ្រាវមួយស្តីពីជំនួយផ្នែកច្បាប់នៅកម្ពុជា ចេញផ្សាយក្នុងខែធ្នូ ឆ្នាំ ២០០៦ ។
- មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីកំពុងមានដំណើរការល្អទៅមុខ
- គណៈមេធាវីមានដំណើរការជាប្រក្រតី និងមានអង្គភាពផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ដែលមាន ការជួយឧបត្ថម្ភពីថវិការដ្ឋ ចំនួន ២០០ លានរៀល ក្នុងមួយឆ្នាំ

- គណៈមេធាវី បានពិនិត្យច្បាប់លក្ខន្តិកៈមេធាវីឡើងវិញរួចហើយ ដើម្បីពិនិត្យសម្រួល មាត្រាពាក់ព័ន្ធ នឹងការអនុញ្ញាតឱ្យមន្ត្រីរាជការ ដាក់ពាក្យសុំចូលធ្វើជាមេធាវី
- ក្រមសីលធម៌មេធាវីកំពុងតែត្រូវបានអនុវត្តជាប្រចាំ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី បានផលិតមេធាវីចំនួន ៤០០នាក់ រួចមកហើយ។ បច្ចុប្បន្ននេះ មាន មេធាវីចំនួនប្រមាណ ៥០០នាក់ កំពុងប្រកបអាជីវកម្មនេះ។

ទិសដៅជាយុទ្ធសាស្ត្រទី ៥ ៖

ទិសដៅជាយុទ្ធសាស្ត្រទី ៥ គឺការពង្រឹងសេវាកម្មយុត្តិធម៌ មានទាំងខាងតុលាការ ទាំងខាងអយ្យការ ។ លទ្ធផលដែលរំពឹងទុកពីទិសដៅនេះ គឺការធានាអោយមានតុលាការ មួយឯករាជ្យ និងមានដំណើរការល្អប្រសើរ ។

សកម្មភាពដែលត្រូវធ្វើក្នុងទិសដៅនេះ មានជាអាទិ៍ ការតាក់តែងច្បាប់ពាក់ព័ន្ធ ដែលយើងបានឃើញរួច ហើយក្នុងទិសដៅជាយុទ្ធសាស្ត្រទី ២ ការពង្រឹងសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា និងមន្ត្រីតុលាការផ្សេងទៀត ការបណ្តុះបណ្តាល ការគ្រប់គ្រងរឿងក្តី ការបំពាក់សម្ភារៈបរិក្ខារ ការរៀបចំតុលាការឯកទេស ការបង្កើតស្ថាប័ន អនុវត្តសាលក្រម-សាលដីកា ។

លទ្ធផលជាក់ស្តែងមាន ៖

- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានអនុម័តក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា រួចហើយនៅ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧ ហើយបច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌កំពុង ត្រៀមរៀបចំសេចក្តីព្រាង ក្រមសីលធម៌មន្ត្រី តុលាការដទៃទៀត
- កំពុងរៀបចំបង្កើតគម្រោងតុលាការគំរូសម្រាប់ខេត្តចំនួនបីទៀតគឺ តុលាការភ្នំពេញ តុលាការខេត្ត កំពង់ចាម តុលាការខេត្តបន្ទាយមានជ័យ បន្ថែមលើតុលាការខេត្ត កណ្តាល
- អង្គការនីតិបញ្ញត្តិបានអនុម័តផ្តល់ថវិកាជូនក្រសួងយុត្តិធម៌ ដើម្បីសាងសង់តុលាការខេត្តចំនួនបី គឺ ខេត្តក្រចេះ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ និងសាលសវនាការមួយនៅខេត្តបាត់ដំបង
- កំពុងអនុវត្តសេចក្តីណែនាំអំពីការគ្រប់គ្រងសំណុំរឿងក្តីនៅក្នុងតុលាការ
- បានធ្វើការសម្របសម្រួលរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ក្នុងវិធានការ បង្កើតតុលាការ ពាណិជ្ជកម្ម ស្របតាមការសម្រេចរបស់កិច្ចប្រជុំក្រុមប្រឹក្សាកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កាលពីថ្ងៃទី១៦ ទី៣០ ខែសីហា និងទី១៤ ខែកញ្ញា ឆ្នាំ២០០៦ ដែលបានសម្រេចឱ្យបង្កើត តុលាការពាណិជ្ជកម្ម ស្មើនឹងតុលាការថ្នាក់ ដំបូង(ខេត្ត ក្រុង) សភាដោះស្រាយវិវាទពាណិជ្ជកម្ម នៅ សាលាឧទ្ធរណ៍ និងសភា ដោះស្រាយវិវាទពាណិជ្ជកម្ម នៅតុលាការកំពូល ។
- ក្រសួងពាណិជ្ជកម្មកំពុងធ្វើការសិក្សាលំអិតអំពីការបង្កើតតុលាការពាណិជ្ជកម្មនេះ
- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការមានដំណើរការល្អ និងកំពុងរៀបចំការបណ្តុះបណ្តាលសារការី និង អាជ្ញាសាលា។ ចៅក្រម និង

ព្រះរាជអាជ្ញាចំនួន ២៩៧ នាក់ បានទទួលសញ្ញាប័ត្រពីសាលាភូមិន្ទ ចៅក្រម ក្រឡាបញ្ជីចំនួន ៧៦៥នាក់ ត្រូវបានបណ្តុះបណ្តាលដោយសាលាភូមិន្ទក្រឡាបញ្ជី

- បានបញ្ចូលគោលការណ៍ក្រមសីលធម៌ចៅក្រម ក្នុងកម្មវិធីបង្រៀននៅសាលាភូមិន្ទ ចៅក្រម និងក្រម សីលធម៌មេធាវីនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី។

ទិសដៅជាយុទ្ធសាស្ត្រទី ៦ ៖

ទិសដៅជាយុទ្ធសាស្ត្រទី ៦ ស្តីពីការបញ្ចូលវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលមាន គោលបំណងជួយរំលែកបន្ទុកតុលាការ និងជួយដោះស្រាយវិវាទតូចតាចនៅកំរិតសហគមន៍ ។

លទ្ធផលជាក់ស្តែងមាន ៖

- ច្បាប់ស្តីពីមជ្ឈត្តកការផ្នែកពាណិជ្ជកម្មបានអនុម័តរួច និងប្រកាសឱ្យប្រើនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ ហើយបច្ចុប្បន្នកំពុងសិក្សារៀបចំមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកម្ម ពាណិជ្ជកម្ម
- កំពុងអនុវត្តអនុសាសន៍ និងការសិក្សាស្ទង់មតិលើវិធីសាស្ត្រសម្រាប់ការដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការ រួមមានការអនុវត្តគម្រោងសិក្សាលទ្ធភាពបង្កើតយន្តការ ដោះស្រាយវិវាទតូចតាច នៅថ្នាក់ មូលដ្ឋាន និងអនុវត្តគម្រោងបង្កើតមជ្ឈមណ្ឌល សេវាកម្មយុត្តិធម៌នៅថ្នាក់ស្រុក ដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ។ គម្រោងបានសាកល្បងបង្កើតមជ្ឈមណ្ឌលចំនួន ២០ និងគណៈកម្មការ ដោះស្រាយវិវាទនៅថ្នាក់ឃុំចំនួន ៧៧
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរាប់ដោះស្រាយវិវាទការងារ កំពុងមានដំណើរការរលូន
- គណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខេត្ត និងជាតិ និងអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី កំពុងដំណើរ ការយ៉ាងសកម្ម។

ទិសដៅជាយុទ្ធសាស្ត្រទី ៧ ៖

ទិសដៅជាយុទ្ធសាស្ត្រទី៧ ជាទិសដៅដែលមានគោលបំណងធ្វើឱ្យស្ថាប័ននៃវិស័យ យុត្តិធម៌ទាំងមូលបំពេញ អាណត្តិរបស់ខ្លួនបានល្អប្រសើរ។ សកម្មភាពក្នុងទិសដៅនេះ ផ្តោតជាពិសេសទៅលើការកសាងសមត្ថភាពមន្ត្រីរាជការ និងការផ្តល់នូវមធ្យោបាយចាំបាច់ សម្រាប់ការធ្វើផែនការ ការរៀបចំថវិកា ការត្រួតពិនិត្យតាមដាន ការធ្វើ របាយការណ៍ ដើម្បីធានាអោយការអនុវត្តការងារ មានការទទួលខុសត្រូវ មានប្រសិទ្ធភាពទទួលបាន លទ្ធផលល្អ។

លទ្ធផលនៃការអនុវត្តទិសដៅទី៧ នេះ ពាក់ព័ន្ធច្រើនដល់លទ្ធផល នៃការអនុវត្ត សកម្មភាពនានា នៃទិស ដៅជាយុទ្ធសាស្ត្រទាំង៦ ខាងលើ។ សកម្មភាពពិសេសរបស់ទិសដៅ ជាយុទ្ធសាស្ត្រទី៧ គឺការណែនាំ និងការបណ្តុះបណ្តាល ផ្នែកធ្វើផែនការ សវនកម្ម ការពិនិត្យតាមដាន។ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ កំពុងធ្វើការជំរុញផ្នែកនេះឱ្យមានការជឿនលឿនទៅមុខ។

ការងារមួយទៀត ដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវនាំមុខដែរនោះ គឺការសិក្សា រៀបចំក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម សម្រាប់សកម្មភាពជាអាទិភាព នៃវិស័យច្បាប់ និងយុត្តិធម៌ ដែលជាមធ្យោបាយដ៏ចាំបាច់ក្នុងការពន្លឿនកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ ដូចមានឧទាហរណ៍ក្នុងវិស័យ អប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ ជាដើម។

លទ្ធផលជាក់ស្តែងមាន ៖

- កំពុងរៀបចំគម្រោងបង្កើតប្រព័ន្ធសូចនាករពិនិត្យតាមដានវិស័យច្បាប់ និងយុត្តិធម៌ ដើម្បីវាស់វែង ការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ
- កំពុងរៀបចំសៀវភៅមគ្គុទេសក៍សម្រាប់វិស័យច្បាប់ និងយុត្តិធម៌ ក្នុងការរៀបចំថវិកា ការធ្វើផែនការ និងការតាមដានត្រួតពិនិត្យនូវចំណាយ
- នាយកដ្ឋានពន្ធនាគារបានបញ្ចប់ផែនការយុទ្ធសាស្ត្រសំរាប់ពន្ធនាគាររួចហើយ ចំណែកក្រសួងមហាផ្ទៃ ក៏បានដាក់ចេញនូវផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ (២០០៨-២០១៣)របស់ខ្លួន កាលពីថ្ងៃ ទី១៤ ខែតុលា ឆ្នាំ២០០៨ រួចហើយដែរ។

## III- សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌ ដែលជាកត្តាគន្លឹះមួយក្នុងចំណោមកត្តាគន្លឹះទាំងបួន នៃអភិបាលកិច្ចល្អ ស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាល។ នៅក្នុងដំណាក់កាលទី១ យើងបានសម្រេចនូវគ្រឹះជាមូលដ្ឋានផ្សេងៗ នៃការកែទម្រង់ គឺការរៀបចំ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងការព្រាងនូវច្បាប់ជាមូលដ្ឋានសម្រាប់យុត្តាធិការតុលាការ។ នៅក្នុងដំណាក់កាលទី២ នៃដំណើរការកំណែទម្រង់ច្បាប់ និងតុលាការ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង នៃ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានកត់សំគាល់ឃើញថា សកម្មភាពជាអាទិភាព ទាំង៩៧ ដែល បានលើកឡើងនៅក្នុងកម្មវិធីសកម្មភាព ដែលរាជរដ្ឋាភិបាលបានអនុម័តកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ នោះ ត្រូវបានអនុវត្តចំនួន ៦០% ទៅហើយ (សូមមើលតារាងគំនូសលេខ ១)។

,

នេះបង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលមានឆន្ទៈយ៉ាងមោះមុតបំផុតក្នុងការធ្វើកំណែទម្រង់ច្បាប់ និង តុលាការនេះ ដូចមានកំណត់នៅក្នុងកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ផែនការ សកម្មភាពអភិបាលកិច្ចទី ២(២០០៥-២០០៨) និងក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០)។

យើងសង្កេតឃើញទៀតថាមានការផ្លាស់ប្តូរឥរិយាបថ របស់សហគមន៍អ្នកផ្តល់ជំនួយមកលើកម្មវិធីសកម្មភាព របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់ច្បាប់ និងតុលាការ។ ប្រទេស និងអង្គការអន្តរជាតិមួយចំនួនបាន ប្រកាន់យកវិធីសាស្ត្រថ្មីក្នុងកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា គឺការបោះជំហ៊ានបន្តិចម្តងៗ ឆ្ពោះទៅរកការជួយ ឧបត្ថម្ភផ្ទាល់

តារាងគំនូសលេខ ១

មកស្ថាប័នរាជរដ្ឋាភិបាលតែម្តង ឧទាហរណ៍ ដូចជាអង្គការ AusAid និង DANIDA តាមរយៈគម្រោង CCJAP ឬអង្គការ UNDP តាមរយៈគម្រោងលទ្ធភាពទទួលបានយុត្តិធម៌ អង្គការ USAID តាមរយៈ វិទ្យាស្ថានគ្រប់គ្រងបស្ទឹម-បូព៌ា JICA និងកម្មវិធីសហប្រតិបត្តិការបារាំង ដែលកំពុងធ្វើសហប្រតិបត្តិការផ្ទាល់ ជាមួយក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវី និងមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវី ជាដើម។

ក្រៅពីចំណុចជាវិជ្ជមានទាំងនេះ យើងក៏មានបញ្ហាប្រឈមដែលត្រូវដោះស្រាយដែរ ដូចជាបញ្ហាធនធាន មនុស្ស និងថវិកា។ ប៉ុន្តែរាជរដ្ឋាភិបាលមិនដែលព្រងើយកន្តើយចំពោះបញ្ហាទាំងនោះឡើយ។ មានការខំប្រឹងប្រែង ជាច្រើនក្នុងការពង្រឹងសមត្ថភាពដឹកនាំ គ្រប់គ្រង និងអនុវត្តកម្មវិធីឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើង និងមាន ប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ តាមរយៈការខិតខំធ្វើទំនាក់ទំនង សម្របសម្រួល ស្វែងរកជំនួយឧបត្ថម្ភ និងការគាំទ្របន្ថែមឱ្យកាន់តែច្រើនទៀត ទាំងផ្នែកបច្ចេកទេស និងថវិកា ដើម្បីរុញច្រានការអនុវត្តកម្មវិធីឱ្យបាន លឿន និងគ្រប់ជ្រុងជ្រោយ។

## IV- ទិសដៅសម្រាប់អនុវត្តបន្ត

ស្របទៅតាមផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី ២ របស់រាជរដ្ឋាភិបាល ការងារដែលត្រូវអនុវត្តជាបន្តសម្រាប់អាណត្តិទី ៤ នៃរដ្ឋសភានេះ រួមមាន ៖

- ពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាវិន័យ ដោយយកបញ្ហាសមាសភាពមកពិនិត្យ ឡើងវិញ
- បោះពុម្ព វិភាគ ផ្សព្វផ្សាយ និងដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅសាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា ដោយមានការបូកបន្ថែមម៉ោង និងបន្ថែមមេគុណនូវសាលក្រម សាលដីការបស់តុលាការ
- ជំរុញឱ្យនីតិវិធីតាក់តែងច្បាប់ចេញបានឆាប់
- ជំរុញការអនុវត្តគម្រោង ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ និងសេរីភាពបុគ្គល នៅថ្នាក់សហគមន៍ មូលដ្ឋាន
- បង្កើតការិយាល័យដើម្បីការពារសិទ្ធិពលរដ្ឋ (Ombudsman)
- ជំរុញការអនុម័តច្បាប់ដែលបានបញ្ជូនទៅរដ្ឋសភា
- ពង្រឹងជំនួយផ្នែកច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រ
- ជំរុញការបង្កើតតុលាការពិសេស/សភាពិសេស តាមតម្រូវការ (តុលាការពាណិជ្ជកម្ម រដ្ឋបាល ការងារ អនីតិជន ។ល។)
- ជំរុញការអនុវត្តគម្រោងតុលាការគំរូឱ្យមានប្រសិទ្ធភាពខ្ពស់ ហើយពង្រីកទៅខេត្តមួយចំនួនទៀត
- ផ្តល់សំភារៈ និងអគារសមស្របដល់តុលាការ
- តាក់តែងក្រមសីលធម៌សម្រាប់មន្ត្រីតុលាការផ្សេងទៀត

- ជំរុញបង្កើត និងពង្រឹងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឱ្យបានច្រើនតាមលទ្ធភាព

- ពង្រឹងសមត្ថភាពមន្ត្រីរាជការតាមក្រសួង ស្ថាប័នពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌

- បញ្ចប់ការរៀបចំសៀវភៅមគ្គុទេសក៍សម្រាប់វិស័យច្បាប់ និងយុត្តិធម៌

- រៀបចំប្រព័ន្ធសូចនាករតាមដានសម្រាប់វិស័យច្បាប់ និងយុត្តិធម៌ទាំងមូល ដើម្បីវាស់វែងភាពជឿន លឿននៃការអនុវត្តកម្មវិធីសកម្មភាព

- សហការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងការអនុវត្តទិសដៅជាយុទ្ធសាស្ត្រទី ៧ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

- បន្តធ្វើការផ្សព្វផ្សាយ ទំនាក់ទំនង និងសម្របសម្រួល ដើម្បីជំរុញការអនុវត្តសកម្មភាពសម្រាប់កំណែ ទម្រង់ច្បាប់ និងតុលាការ ដែលនៅសេសសល់ឱ្យបានលឿន និងឱ្យបានច្រើនថែមទៀត។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩

អ្នកធ្វើរបាយការណ៍

**អគ្គលេខាធិការ**

**ស៊ុយ ម៉ុងលាង**